**Declassified to Public**
**25 January 2019**

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 15-May-2018, 08:17
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សម្ងាត់/Confidential**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សារណារបស់សហមេធាវីអន្តរជាតិរបស់ នួន ជា**

**ស្តីអំពីឋានៈរបស់គាត់ក្នុងសំណុំរឿង ០០២/០២**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីអន្តរជាតិរបស់ នួន ជា**

Victor KOPPE

**<u>ផ្ញើជូន</u>៖**

**សហមេធាវីជាតិរបស់ នួន ជា**

លោក សុន អរុណ

**សហមេធាវីរបស់ ខៀវ សំផន**

លោក គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang

Marie GUIRAUD

១. ខ្ញុំយោងទៅលើអនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃ ០២ ខែ ឧសភា ឆ្នាំ ២០១៨ ("អនុស្សរណៈ") ដែលបានបង្គាប់មកលោក Isaac Endeley និង រូបខ្ញុំ[1]។

២. អនុស្សរណៈស្នើឲ្យខ្ញុំ "ស្នើសុំចុះឈ្មោះជាបន្ទាន់នៅក្នុងបញ្ជីគណៈមេធាវីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ *ក្រៅពីប្រទេសកម្ពុជា* ឲ្យបានត្រឹមថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨"[2] ។ អនុស្សារណៈក៏បានស្នើឲ្យខ្ញុំ "បំពេញនិយ័តកម្មជាមួយនឹងគណៈមេធាវីបរទេសទាក់ទងនឹងស្ថានភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦"[3]។ ជាជម្រើសម្យ៉ាងទៀត អនុស្សរណៈស្នើឲ្យខ្ញុំដាក់សារណាដែលពាក់ព័ន្ធនឹងកម្មវត្ថុនេះ មិនឲ្យហួសពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨។

៣. យោងទៅលើអនុស្សរណៈ មូលដ្ឋានច្បាប់សម្រាប់ការស្នើសុំនេះហាក់ដូចជា៖

> អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានលក្ខខណ្ឌដែលអត្ថិភាព និងចាំបាច់ដែលថា សហមេធាវីអន្តរជាតិ ក្នុងពេលបច្ចុប្បន្ន ត្រូវតែជាសមាជិកនៃគណៈមេធាវីដែលមានកិត្តិនាមល្អ និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេស ដែលជាសមាជិកអង្គការសហប្រជាជាតិ ក្រៅពីប្រទេសកម្ពុជា ហើយថា [ខ្ញុំ] បានរំលោភបំពានលើលក្ខខណ្ឌនេះ ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មក។

៤. ដោយយោងលើអង្គជំនុំជម្រះ "លក្ខខណ្ឌនេះគឺឆ្លុះបញ្ចាំងនៅក្នុងការវាយតម្លៃជារួមនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ទាក់ទងនឹងសម្បទាផ្លូវច្បាប់របស់មេធាវីអន្តរជាតិ ដែលប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក"[4]។

---

[1] E378/8/2 "ឋានៈរបស់សហមេធាវីការពារក្តីលោក នួន ជា ក្នុងសំណុំរឿង ០០២/០២" ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៨ (អនុស្សរណៈ) កថាខណ្ឌ ៩។

[2] E378/8/2 អនុស្សរណៈ កថាខណ្ឌ ៩ (បញ្ជាក់បន្ថែម)។

[3] E378/8/2 អនុស្សរណៈ កថាខណ្ឌ ៩ (បញ្ជាក់បន្ថែម)។

[4] E378/8/2 អនុស្សរណៈ កថាខណ្ឌ ៩ (បញ្ជាក់បន្ថែម)។

៥. បើទោះជា អនុស្សរណៈយោងយ៉ាងច្រើនពីអនុស្សរណៈថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៨ របស់ប្រធានអង្គភាពគាំពារការការពារក្ដីលោក Isaac Endeley (អនុស្សារណៈរបស់អង្គភាពគាំពារការការពារក្ដី)[5] ក៏ដោយ ក៏អនុស្សរណៈរបស់អង្គជំនុំជម្រះមិនបានលើកឡើងអំពីចំនុចសំខាន់ដែលលើកឡើងដោយលោក Isaac Endeley ដែលលើកឡើងថា៖

> វាក៏អាចតម្រូវផងដែរឲ្យធ្វើការកែប្រែទៅលើបទប្បញ្ញាត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុង បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី និងកិច្ចសន្យាផ្ដល់សេវាផ្នែកច្បាប់ដែលមេធាវីការពារក្ដីបានចុះហត្ថលេខា ដើម្បីជាលក្ខខណ្ឌតម្រូវយ៉ាងច្បាស់លាស់ឲ្យគ្រប់មេធាវីបរទេសទាំងអស់នៅ អ.វ.ត.ក ផ្ដល់ភ័ស្ដុតាងបញ្ជាក់ឲ្យបានទៀងទាត់តាមពេលវេលាកំណត់អំពីសមាជិកភាពនៃគណៈមេធាវីនៅក្រៅប្រទេសកម្ពុជា[6]។

៦. បើតាមខ្ញុំដឹងរហូតមកដល់ពេលនេះ គឺពុំទាន់មានការផ្ដួចផ្ដើមធ្វើទៅលើច្បាប់ និងបទបញ្ជាដែលបានលើកឡើងខាងលើនេះទេ ហើយក៏ពុំមានពង្រាងកិច្ចសន្យាសេវាផ្នែកច្បាប់ដែលតម្រូវឲ្យមានការបង្ហាញអំពីសមាជិកភាពនៅគណៈមេធាវីនៅក្រៅប្រទេសកម្ពុជានៅឡើយ ។

៧. វាពិតណាស់ថា នេះមិនមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការវិតក្កិតតែឯកតោភាគីទៅលើការងារកិច្ចសន្យាផ្នែកច្បាប់រវាងអង្គការសហប្រជាជាតិ និង មេធាវីការពារក្ដីនោះទេ ជាពិសេសនៅពេលដែលភាគីចុះកិច្ចសន្យាព្រមព្រៀងទៅលើខ្លឹមសារ និងពុំមានការជំទាស់ផ្នែកច្បាប់ណាមួយនោះ។

៨. ដូចដែលបានបញ្ជាក់នៅក្នុងលិខិតជាសម្ងាត់របស់ខ្ញុំជូនលោក Endeley នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៨ ដែលខ្ញុំត្រូវបានប្រាប់ដោយអ្នកគ្រប់គ្រងមុនគាត់ នៅឆ្នាំ ២០០៨ ហើយខ្ញុំតែងតែយល់ថា ការងារច្បាប់ និងច្បាប់ដែលពាក់ព័ន្ធគឺថា សមាជិកភាពនៅគណៈមេធាវីបរទេសចាំបាច់តម្រូវឲ្យ

---

[5] **E378/8/1** “ឋានៈរបស់សហមេធាវីអន្តរជាតិ ក្នុងសំណុំរឿង ០០២/០២” ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៨ (អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្ដី)។

[6] **E378/8/1** អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្ដី, កថាខណ្ឌ ៤។

មាននៅតែពេលទទួលស្គាល់ដើម្បីដាក់ចូលទៅក្នុងបញ្ជីមេធាវីរបស់អង្គភាពគាំពារការការពារក្តី និង បញ្ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោក Endeley ដែលជាអ្នកបន្តវេនពីភាគីកិច្ចសន្យាជាមួយខ្ញុំនៅឆ្នាំ ២០០៨ យល់ស្របទាំងស្រុងជាមួយការបកស្រាយរបស់ខ្ញុំអំពីកិច្ចសន្យាការងារនេះ ដូចដែលគាត់បានបញ្ជាក់យ៉ាងច្បាស់នៅកថាខណ្ឌ ៣ នៃអនុស្សរណៈរបស់អង្គភាពគាំពារការពារក្តី[7]។

៩. ដូចនេះហើយខ្ញុំសុំលើកជូនអង្គជំនុំជម្រះនូវវិធាន ២ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលចែងថា៖

> នៅក្នុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្តដោយស្របទៅលើមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬ ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍មូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

១០. ដូចដែលអង្គជំនុំជម្រះជ្រាបហើយថា មាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក តម្រូវឱ្យសវនាការនៅ អ.វ.ត.ក ត្រូវប្រព្រឹត្តឱ្យបាន "ត្រឹមត្រូវ" "ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ" និង "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ" ("ICCPR") ។ ខ្ញុំពិតជាមិនចាំបាច់រំលឹកដល់អង្គជំនុំជម្រះអំពីមាត្រា ១៤ នៃ ICCPR និងក៏មិនបាច់លើកឡើងអំពីមាត្រា

---

[7] **E378/8/1** អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្តី, កថាខណ្ឌ ៤។ សូមមើលជាពិសេស "ការបង្ហាញភស្តុតាងអំពីសមាជិកភាពនៅគណៈមេធាវីបរទេស គឺតម្រូវតែនៅពេលមានសំណើសុំឱ្យចុះឈ្មោះក្នុងបញ្ជីឈ្មោះមេធាវីរបស់ អ.គ.ក ប៉ុន្តែក្រោយមកទៀតមិនតម្រូវបែបនេះទេ"។

៣៥ថ្មី នៃច្បាប់ អ.វ.ត.ក ដែលធានាដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការមានមេធាវីតាមការជ្រើសរើសដោយខ្លួនឯង។

១១. វាអាចថា នៅក្នុងកិច្ចប្រជុំពេញអង្គ អង្គជំនុំជម្រះតុលាការកំពូល (“អជតក”) ចៅក្រម និង/ឬ ចៅក្រមផ្សេងទៀតនៅ អ.វ.ត.ក យល់ព្រមជាមួយលោក Endeley និង ខ្ញុំ។ ជំហររបស់ចៅក្រមតុលាការកំពូលនៅកិច្ចប្រជុំពេញអង្គ ចំពោះបញ្ហានេះគឺពិតជាពាក់ព័ន្ធ ដោយសារតែគាត់នឹងចាប់ផ្តើមសវនាការទៅលើបណ្តឹងសាទុករបស់លោក នួន ជា នៅក្នុងសំណុំរឿង ០០២/០២ ដែលរំពឹងថា នឹងកើតឡើងនៅពេលណាមួយនៅក្នុងឆ្នាំនេះ។ ទោះជានៅក្នុងករណីណាក៏ដោយ ក៏វាលំបាកក្នុងការគិតថា គាត់នឹងផ្អែកទៅលើជំហររបស់គាត់ទៅលើ “ការបកស្រាយ*ជារួម*” នៃច្បាប់ជាធរមាន[8]។ បើតាមខ្ញុំយល់ អ.វ.ត.ក ចាត់ទុកខ្លួនឯងជា ស្ថាប័នច្បាប់ និងមិនមែនជាកន្លែងហាត់យ៉ូហ្គានោះទេ។

១២. ការព្រួយបារម្ភចំបងរបស់អង្គជំនុំជម្រះគឺហាក់ដូចជាផ្តោតទៅលើការទទួលខុសត្រូវរបស់ខ្ញុំទៅលើកំហុសវិជ្ជាជីវៈ។ មកទល់នឹងពេលនេះអង្គជំនុំជម្រះបានដាក់ពាក្យបណ្តឹងចំនួនបីផ្សេងគ្នាទៅគណៈមេធាវីអាំស្ទែដាំ អំពីការចោទប្រកាន់អំពីកំហុសវិជ្ជាជីវៈដែលបានប្រព្រឹត្តដោយរូបខ្ញុំនៅក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០២។ ដូចដែលអង្គជំនុំជម្រះដឹងហើយថា ប្រធានគណៈមេធាវីអាំស្ទែដាំមិនទទួលយកបណ្តឹងទាំងនេះទេ ហើយបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យ។ អ្វីដែលប្រហែលជាអង្គជំនុំជម្រះមិនបានដឹងនោះ គឺថានឹងមានសវនាការមួយទៅលើបណ្តឹងទាំងនេះនៅថ្ងៃច័ន្ទទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ នៅអាំស្ទែដាំ។

១៣. បណ្តឹងទីបីរបស់អង្គជំនុំជម្រះគឺអំពីលទ្ធភាពនៃកំហុសវិជ្ជាជីវៈរបស់ខ្ញុំ នៅខែ ឧសភា ឆ្នាំ ២០១៧។ ខ្ញុំបានលើកឡើងទៅប្រធានគណៈមេធាវីអាំស្ទែដាំថា គាត់មានសមត្ថកិច្ចក្នុងដោះស្រាយបញ្ហានេះ។ ហើយខ្ញុំក៏នឹងលើកឡើងផងដែរនៅសវនាការថ្ងៃទី ០៤ មិថុនា ឆ្នាំ ២០១៨ ថា ក្រុមប្រឹក្សាវិន័យ មានសមត្ថកិច្ចដូចគ្នាក្នុងការសម្រេចលើបញ្ហានេះ។ តាមយោ

---

[8] **E378/8/2** អនុស្សរណៈ កថាខណ្ឌ ២ (បញ្ជាក់បន្ថែម)។

បល់របស់ខ្ញុំ ការដែលខ្ញុំមិនមិនបានចុះឈ្មោះនៅគណៈមេធាវីអាំស្ទែដាំ ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ គឺមិនរារាំងដល់ក្រុម ប្រឹក្សាក្នុងការសម្រេចលើបញ្ហានេះទេ។ នៅបន្ទាប់ពីពិភាក្សាជាមួយក្រឡាបញ្ជីនៃក្រុមប្រឹក្សាវិន័យរួចមក ខ្ញុំរំពឹងថា សេចក្តីសម្រេចលើបណ្តឹងទាំងបីនេះ នឹងចេញនៅក្នុងរយៈប្រាំមួយសប្តាហ៍នៅបន្ទាប់ពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨។ ប្រសិនបើក្រុមប្រឹក្សាយល់ស្របដូចខ្ញុំ ហើយខ្ញុំអាចទទួលខុសត្រូវលើកំហុសវិជ្ជាជីវនៅក្នុងដំណើរការនីតិវិធីនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ នោះ "ស្ថានការនឹងទទួលបាននិយ័តកម្ម"។ ខ្ញុំមិនមើលឃើញវិធីផ្សេងទៀតក្នុងការ "បំពេញនិយ័តកម្មនៃស្ថានការ" ដូចដែលអង្គជំនុំជម្រះទាមទារនោះទេ ដោយសារតែវាត្រូវតែច្បាស់សម្រាប់គ្រប់គ្នាថា ខ្ញុំមិនអាចក្លាយជាសមាជិកនៃគណៈមេធាវីអាំស្ទែដាំដោយប្រតិសកម្មនោះទេ។ ប្រសិនបើអង្គជំនុំជម្រះគិតថា ខ្ញុំអាចធ្វើបាន សូមបង្ហាញខ្ញុំថា តាមវិធីបែបណាដែលនឹងអាចធ្វើទៅបាន។

១៤. នៅគ្រប់ករណីទាំងអស់ នេះមិនបានផ្លាស់ប្តូរទៅលើការពិតដែលខ្ញុំនៅតែជាសមាជិកមានកិត្តិនាមល្អនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ដូចដែលអង្គជំនុំជម្រះដឹងហើយថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានច្បាប់យ៉ាងរឹងមាំទៅលើអ្វីដែលត្រូវចាត់ទុកជាកំហុសវិជ្ជាជីវទៅលើសមាជិករបស់ខ្លួន។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាអាចដាក់ឱ្យខ្ញុំទទួលខុសត្រូវលើកំហុសវិជ្ជាជីវ ដែលខ្ញុំអាចប្រព្រឹត្តខុសនៅក្នុងអំឡុងពេលដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយដាក់វិន័យមកលើរូបខ្ញុំ។ ខ្ញុំអាចនៅចាំថា អជតក បានដាក់បណ្តឹងប្រឆាំងទៅលើសហភាតាជាតិរបស់ខ្ញុំចំពោះការប្រព្រឹត្តរបស់គាត់នៅក្នុងអំឡុងពេលខែ វិច្ឆិកា ឆ្នាំ ២០១៥។ តើអ្វីដែលជាគោលបំណងដែលតម្រូវឱ្យមេធាវីអន្តរជាតិត្រូវតែជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយបន្ទាប់មកយកទៅស្បថ នៅចំពោះមុខតុលាការកំពូលភ្នំពេញ?

១៥. តាមពិតទៅ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចសាកសមជាងក្នុងការដោះស្រាយលើបណ្តឹងលើកទីបី ព្រោះវាពាក់ព័ន្ធទៅនឹងការរំលោភការសម្ងាត់ ដែលប្រព្រឹត្ត

ដោយខ្ញុំ ដែលត្រូវចោទប្រកាន់ថា បានផ្តល់ទៅកាសែត *Cambodian Daily* សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដែលត្រូវបានចំណាត់ថ្នាក់សម្ងាត់ទៅ។ រហូតមកដល់ពេលនេះ តាមដែលខ្ញុំដឹង អ្នកកាសែតរូបនោះនៅតែកំពុងធ្វើការនៅភ្នំពេញនៅឡើយ ហើយការរកកំហុសណាមួយអាចធ្វើទៅបានដោយមានប្រសិទ្ធិភាពនៅភ្នំពេញ លើកលែងតែអង្គជំនុំជម្រះ យល់ថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មិនសមក្នុងការដោះស្រាយទៅលើបញ្ហាវិន័យចំពោះសមាជិករបស់ខ្លួន។ ប្រសិនបើដូច្នេះមែន នោះវាពិតជាគំនិតគួរឲ្យសោកស្តាយមួយ។

១៦. ដើម្បីបញ្ចប់សារណានេះ ខ្ញុំសូមស្នើថា យើងគួរតែចាំសេចក្តីសម្រេចពីក្រុមប្រឹក្សាវិន័យ និងការកំណត់នៃដំណើរការនៃការចរចារធ្វើកិច្ចសន្យាថ្មីរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរូបខ្ញុំ។ ហើយសម្រាប់ សំណើតាមផ្លូវច្បាប់សម្រាប់ធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ខ្ញុំជឿជាក់ថា លោក Endeley នឹងចាប់ផ្តើមនូវការផ្តួចផ្តើមសម្រាប់ដំណើរការនេះ។

**សហមេធាវីអន្តរជាតិរបស់ នួន ជា**



Victor KOPPE